**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

លេខ : ៣០៧៦ ជនស/អរប

ថ្ងៃព្រហ. ៤រោច ខែមិគសិរ ឆ្នាំរកា ព.ស.២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ ធ្នូ គ.ស. ២០១៧

**ជម្រាបជូន**

**ឯកឧត្តម លោកជំទាវអភិបាលនៃគណៈអភិបាល និងជា**

**ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត**

**កម្មវត្ថុ:** ការចូលរួមកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ

**យោង:** -អនុក្រឹត្យលេខ ៨៦ អនក្រ.បក ចុះថ្ងៃទី ១៩ ខែធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលិខិតអនុញ្ញាតសាងសង់

-អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ០៣ ខែមេសា ឆ្នាំ ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលនិងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត** ជ្រាបថា ដើម្បីធានាសុវត្ថិភាព សុខុមាលភាព និងភាពងាយស្រួលសម្រាប់មនុស្សទាំងអស់គ្នា ជាពិសេសកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិស្នើសុំ **ឯកឧត្តម លោកជំទាវ** ដាក់ចែងឱ្យមានហេដ្ឋារចនាសម្ព័ន្ធ ទីកន្លែង បរិក្ខារ និងសេវាសម្រាប់ជនពិការគ្រប់ប្រភេទ ដូចជា ការរៀបចំផ្លូវជម្រាល ផ្លូវដើរ ជណ្តើរ បង្កាន់ដៃសុវត្ថិភាព ភ្លើងសញ្ញា ស្លាកសញ្ញា និងបរិក្ខារជំនួយសុវត្ថិភាពផ្សេងៗ សម្រាប់ជនពិការ ចំពោះរាល់គម្រោងអភិវឌ្ឍ ជាអាទិ៍÷

- គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈ សំណង់ផ្តល់សេវាជូនសាធារណជន និងលំហសាធារណៈ ដូចជា បណ្តាញផ្លូវ ផ្លូវថ្មើរជើង ចិញ្ចើមផ្លូវ សួនច្បារ ចំណតយានយន្ត ស្ថានីយ៍រថភ្លើង ព្រលានយន្តហោះ អគាររដ្ឋបាល សាលារៀន គ្រឹះស្ថានអប់រំ មន្ទីរពេទ្យ មណ្ឌលសុខភាព។
- គម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធ សំណង់បុរី លំនៅឋាន សណ្ឋាគារ ភោជនីយដ្ឋាន ផ្សារ រោងចក្រ និងអគារឯកជនផ្សេងៗទៀត។



អាសយដ្ឋាន : ដីឡូត៍លេខ ៧៧១-៧៧៣ មហាវិថីព្រះមុនីវង្ស សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ/ទូរសារ (855) 23 215 660 / 23 215 277 គេហទំព័រ www.mlmupc.gov.kh អ៊ីមែល mlmupc.cabinet@gmail.com

អាស្រ័យហេតុនេះ សូម **ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាល និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត** ជ្រាប និងអនុវត្ត។

សូម **ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាល និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត** ទទួលនូវការរាប់អានពីខ្ញុំ។

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា**
**ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

**ចម្លងជូន÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងសុខាភិបាល
- ក្រសួងបរិស្ថាន
- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ក្រសួងអប់រំ យុវជន និងកីឡា
- មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានី ខេត្ត
- ឯកសារ កាលប្បវត្តិ